ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២/១៣-វីនសុន អ៊ីនធល ហ្គាមិន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ហួន ជុនឌី**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន វីនសុន អ៊ីនធល ហ្គាមិន (ខេមបូឌា) អិលធីឌី**
អាសយដ្ឋាន ៖ ភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ ៖ ០១២ ៦៣២ ៦៤២, ០៩២ ៦៣ ៦៤ ១៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក នព្វ មានិត | មេធាវី |
| ២- លោក ឆាយ ហួត | ជំនួយការអគ្គនាយក |
| ៣- លោក កង វ៉ាន់ណែត | បុគ្គលិករោងចក្រ |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**
អាសយដ្ឋាន ៖ ផ្ទះលេខ ១៦ A ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៧ ៥៥២ ៤៥២ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ អវត្តមាន


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ក្រុមហ៊ុនមិនទទួលយកឈ្មោះ ហ៊ល រ៉ា, ដួង សុខុម និង យុត ថេត ឱ្យចូលបំរើការងារវិញទេ។

២-ស្នើឱ្យក្រុមហ៊ុនតម្លើងប្រាក់ខែគោល ៧០ ដុល្លារ។

៣(៥)-ពេលកម្មករធ្វើការទល់ភ្លឺ សូមឱ្យក្រុមហ៊ុនគិតលុយឱ្យបានត្រឹមត្រូវ។

៤(៦)-ពេលកម្មករសុំច្បាប់ឈប់សម្រាក សូមកុំឱ្យក្រុមហ៊ុនកាត់លុយព្រីម។

៥(៧)-ពេលកម្មករឈប់សម្រាកឈឺមានសំបុត្រពេទ្យ សុំកុំឱ្យក្រុមហ៊ុនកាត់លុយ។

៦(៨)-ពេលកម្មករមកយឺត សុំកុំឱ្យក្រុមហ៊ុនកាត់លុយ។

៧(៩)-ពេលឡានខូច សុំឱ្យក្រុមហ៊ុនទៅយក។

៨(១០)-អំឡុងពេលកូដកម្ម សុំកុំឱ្យក្រុមហ៊ុនកាត់លុយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០២៩/១៣ កប/កស្ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ (វេលាម៉ោង ០៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ មានករណីកូដកម្មមួយនៅក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ វីនសុន អ៊ីនធល ហ្គាមិន (ខេមបូឌា) អិលធីឌី ដែលបង្កឡើងដោយកម្មករនិយោជិត និងដឹកនាំដោយសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានទទួលពាក្យបណ្តឹងអំពីករណីកូដកម្មនេះ ហើយបានបានចាត់មន្ត្រីជំនាញទៅដល់កន្លែងធ្វើកូដកម្ម និងបានធ្វើការ

ផ្សះផ្សា ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច លើចំណុចវិវាទ ចំនួន ១០ ចំណុច គឺចំណុចវិវាទទី ៣ និង ចំណុចវិវាទទី៤។ ដោយឡែក ចំណុចមិនសះជាចំនួន ០៨ ចំណុចទៀត គឺចំណុចវិវាទទី១, ២ ,៥ ,៦ ,៧ ,៨ , ៩ និងទី១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៣ តាមរយៈ របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ០២៩/១៣ ក.ប/កស្ក ចុះថ្ងៃ ទី១៥ ខែមករា ឆ្នាំ២០១៣។

កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៣ នៅវេលាម៉ោង ១៤៖០០ នាទី រសៀល។ ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយបានអះអាងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម រហូតមកដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ នេះ។ ប៉ុន្តែភាគីកម្មករនិយោជិតមិនមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- ដីកាសម្រេចរក្សាការពាររបស់សាលាដំបូងខេត្តកំពង់ស្ពឺ លេខ ០៦ (ង) ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៣។

២- ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន វីនសុន អ៊ិនធល ហ្គាមិន ។

៣- លិខិតជូនដំណឹងលេខ ៦០ រប/២០១៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ជម្រាបមកតំណាងក្រុមហ៊ុន វីនសុន ជូនដំណឹងពីការចុះអនុវត្តដីកាសម្រេចរក្សាការពារលេខ ០៦ (ង) ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីនសុន អ៊ិនធល ហ្គាមិន (ខេមបូឌា) អិលធីឌី លេខ ០២៩/១៣ កប/កស្ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វីនសុន អ៊ិនធល ហ្គាមិន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ០៦៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែ

THE ARBITRATION COUNCIL

មករា ឆ្នាំ២០១៣ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួម ផ្តល់ព័ត៌មាន លេខ ០៦៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *“ក្នុងអំឡុងពេល នៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ)* ***ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។*** *ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ”* ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ូ លេខ៣៩/០៨-ចុង យ៉ូវ និងលេខ ១៣៧/០៩ និង ១៣៨/០៩-ញ៉ូ ភាញ់ និង លេខ ១១០/១១- ស៊ីម៉ាណូ)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះនៅថ្ងៃ ទី២១ ខែមករា ឆ្នាំ២០១៣។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយតាមរយៈការលើកឡើងរបស់ភាគីនិយោជក កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មមកដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ នេះ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ ។

THE ARBITRATION COUNCIL

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## **សម្រេច និង បង្គាប់**

- មិនបន្តដំណើការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១២/១៣-វីនសុន អ៊ីនធល ហ្គាមិន។

### **ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ហួន ជុនឌី**

ហត្ថលេខា ៖ ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ----------------------------------------